ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តរតនគិរី

លេខៈ ១១០........./១៥ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការ ជម្រុញចលនា ភូមិ១ ផលិតផល១ ខេត្តរតនគិរី

## អភិបាល នៃគណៈអភិបាលខេត្តរតនគិរី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជម្រុញចលនាភូមិមួយ ផលិតផលមួយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/១០៥៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជម្រុញចលនាភូមិមួយ ផលិតផលមួយ ដោយធ្វើសមាហរណកម្មការងារជម្រុញចលនា ភូមិមួយ ផលិតផលមួយ ឲ្យស្ថិតក្រោមការទទួលខុសត្រូវ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៤/៥២៩ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤ ដែលត្រាស់បង្គាប់តែងតាំង អភិបាល នៃគណៈអភិបាលខេត្តរតនគិរី
- យោងលិខិតលេខ ០២៩ ភ១ ផ១ ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ស្តីពីការរៀបចំគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តរតនគិរី

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការខេត្ត ជម្រុញចលនាភូមិ១ ផលិតផល១ សរសេរអក្សរកាត់ថា (គ.ខ.ភ១ ផ១) ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ថង សាវុន** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. ឯកឧត្តម | **ញ៉ែម សំអឿន** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. លោក | **សេក ហៃ** | នាយករដ្ឋបាលសាលាខេត្ត | លេខាធិការ |
| ៤. លោក | **សយ សុណា** | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ៥. លោក | **អ៊ាច ហៃ** | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត | សមាជិក |
| ៦. លោក | **គូ ឆាន់ញុំ** | ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ៧. លោក | **ខៃត ពិន្ទុ** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ៨. លោក | **អ៊ុក សំអុល** | អភិបាល នៃគណៈអភិបាលក្រុងបានលុង | សមាជិក |
| ៩. លោក | **ឌុំ ទិល** | អភិបាល នៃគណៈអភិបាលស្រុកវើនសៃ | សមាជិក |

| | | |
|---|---|---|
| ១០. លោក **ហោច មុន្ន** | អភិបាល នៃគណៈអភិបាលស្រុកបរកែវ | សមាជិក |
| ១១. លោក **ម៉ា ទិចិត្រ** | អភិបាល នៃគណៈអភិបាលស្រុកអូរយ៉ាដាវ | សមាជិក |
| ១២. លោក **នខ ដារិទ្ធ** | អភិបាល នៃគណៈអភិបាលស្រុកអណ្ដូងមាស | សមាជិក |
| ១៣. លោក **ឈឿន ចាន់ឆាខ** | អភិបាល នៃគណៈអភិបាលស្រុកកូនមុំ | សមាជិក |
| ១៤. លោក **គង់ ស្រ៊ុន** | អភិបាល នៃគណៈអភិបាលស្រុកលំផាត់ | សមាជិក |
| ១៥. លោក **មួខ ម៉ាខ** | អភិបាល នៃគណៈអភិបាលស្រុកតាវែង | សមាជិក |
| ១៦. លោក **យ៉ាត គឿ** | អភិបាលស្ដីទី នៃគណៈអភិបាលស្រុកអូរជុំ | សមាជិក |
| ១៧. លោក **សាត ចណ្ណៈ** | នាយកស្ដីទី ទីចាត់ការអន្តរវិស័យសាលាខេត្ត | ជំនួយការ |

**ប្រការ ២.-**

គណៈកម្មាធិការខេត្ត ជម្រុញចលនាភូមិ១ ផលិតផល១ (គ.ខ.ភ១ ផ១) មានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជម្រុញចលនាភូមិ១ ផលិតផល១ ។
- ជម្រុញការអនុវត្តចលនា ភូមិ១ ផលិតផល១ ឲ្យទទួលបានជោគជ័យ ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណជំហានទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ។
- អភិវឌ្ឍធនធានមនុស្សទាក់ទងនឹងការជម្រុញចលនា ភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ដើម្បីអនុវត្តចលនាភូមិ១ ផលិតផល១ ឲ្យបានទទួលជោគជ័យ រួមចំណែកកាត់បន្ថយភាពក្រីក្រ កាត់បន្ថយចំណាកស្រុក លើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតរបស់ប្រជាជន តាមសហគមន៍ ។
- ចូលរួម និងដឹកនាំការសិក្សា ស្រាវជ្រាវផលិតផល ជាសក្ដានុពលនានា ដែលមាននៅក្នុងខេត្ត ផលិតផលជាវត្ថុធាតុដើម ផលិតផលកែច្នៃ និងផលិតផលសេវាកម្មដើម្បីបញ្ចូលទៅក្នុងចលនាភូមិ១ ផលិតផល១ ដោយធ្វើយ៉ាងណាបន្តអភិវឌ្ឍផលិតផលទាំងនេះមានលក្ខណៈកាន់តែប្រសើរ កាន់តែពិសេស និងសមស្របតាមទីផ្សារទាំងក្នុងសហគមន៍ ក្នុងប្រទេស និងក្រៅប្រទេស ។
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីសារៈសំខាន់នៃការជម្រុញចលនាភូមិ១ ផលិតផល១ និងលើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋាន ឲ្យចូលរួមគាំទ្រ និងអនុវត្តចលនានេះ ។
- សម្របសម្រួលជាមួយអង្គការ ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានានៅថ្នាក់ក្រោមជាតិ ដើម្បីជម្រុញការអនុវត្តចលនាភូមិ១ ផលិតផល១ ។
- សម្របសម្រួលរៀបចំអនុវត្តយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ផែនការសកម្មភាពជម្រុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ក្រោមជាតិ ។
- រៀបចំបង្កើតសមាគមឬសហគមន៍គាំទ្រចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត ។
- រៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត សម្រាប់ធ្វើជាកន្លែងសិក្សាស្រាវជ្រាវ បណ្ដុះបណ្ដាល ផ្សព្វផ្សាយ ប្រមូលផ្ដុំ និងដាក់តាំងបង្ហាញ ឬលក់ផលិតផលភូមិ១ ផលិតផល១ ។
- រៀបចំបង្កើតអនុគណៈកម្មាធិការក្រុង ស្រុក ជម្រុញចលនាភូមិ១ ផលិតផល១ ដោយសមាសភាព និងតួនាទីរបស់អនុគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានគណៈ

កម្មាធិការខេត្ត ជម្រុញចលនាភូមិ១ ផលិតផល១ ។

- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជម្រុញចលនាភូមិ១ ផលិតផល១ និងថ្នាក់ដឹកនាំខេត្ត និងចម្លងជូនមន្ទីរស្ថាប័នពាក់ព័ន្ធក្នុងខេត្ត ដើម្បីរួមសហប្រតិបត្តិការក្នុងការជម្រុញចលនាភូមិ១ ផលិតផល១ ។

**ប្រការ ៣.-**

ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការខេត្ត ជម្រុញចលនា ភូមិ១ ផលិតផល១ (គ.ខ.ភ១ ផ១) មានដូចខាងក្រោម ៖

- គ.ខ.ភ១ ផ១ មានសិទ្ធិរៀបចំបែងចែកភារកិច្ចទទួលខុសត្រូវ លម្អិតបន្ថែមទៀតសម្រាប់ជម្រុញចលនាភូមិ១ ផលិតផល១ នៅថ្នាក់ខេត្ត និងក្រុង ស្រុករបស់ខ្លួន ។
- គ.ខ.ភ១ផ១ មានលេខាធិការដ្ឋានមួយ ដឹកនាំដោយនាយករដ្ឋបាល និងមានជំនួយការចំនួនជាមន្ត្រីសាលាខេត្ត ទៅតាមការចាំបាច់ ដោយមានការឯកភាពពីប្រធានគណៈកម្មាធិការខេត្តជម្រុញចលនាភូមិ១ ផលិតផល១ ។
- គ.ខ.ភ១ ផ១ អាចអញ្ជើញតំណាងមន្ទីរ អង្គភាពផ្សេងៗទៀតក្នុងខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ តំណាងវិស័យឯកជន និងតំណាងសហគមន៍ ឬសមាគមចូលរួមប្រជុំផ្តល់យោបល់ ឬពិភាក្សាគ្នាក្នុងការអនុវត្តភារកិច្ចលើកកម្ពស់ចលនាភូមិ១ ផលិតផល១ នៅក្នុងខេត្តរបស់ខ្លួន ។
- សមាជិក គ.ខ.ភ១ ផ១ ត្រូវចូលរួមប្រជុំរៀងរាល់៣ខែម្តង និងករណីពិសេសណាមួយតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការខេត្តជម្រុញភូមិ១ ផលិតផល១ ។
- កិច្ចប្រជុំរៀងរាល់ ៣ខែម្តង ឬករណីពិសេសណាមួយ ត្រូវស្ថិតក្រោមអធិបតីភាពប្រធានគណៈកម្មាធិការខេត្តជម្រុញភូមិ១ ផលិតផល១ ឬអនុប្រធានគណៈកម្មាធិការដែលត្រូវបានទទួលការផ្ទេរសិទ្ធិពីប្រធានគណៈកម្មាធិការ ។

**ប្រការ ៤.-**

រាល់សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយក នាយករងរដ្ឋបាលសាលាខេត្ត នាយកទីចាត់ការ ប្រធានអង្គភាពចំណុះរចនាសម្ព័ន្ធសាលាខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក ប្រធានស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និង ឯកឧត្តម អស់លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រតនគិរី,ថ្ងៃទី.២៥.....ខែ ឧសភា ឆ្នាំ២០១៥

**អភិបាលខេត្ត**

ថន សាវុន

**ចម្លងជូន**

-ក្រសួងមហាផ្ទៃ
-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជម្រុញចលនាភូមិ១ ផលិតផល១
-ក្រុមប្រឹក្សាខេត្ត (ដើម្បីជូនជ្រាប)
-ដូចប្រការ៥ (ដើម្បីអនុវត្ត)
-ឯកសារ កាលប្បវត្តិ